**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល**

# ប្រកាសរួម
# ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល
# ស្តីពី
# ការគ្រប់គ្រងគុណភាព សេវាកម្ម និងវិធានការលុបបំបាត់ផលិតផលសុខាភិបាលខុសច្បាប់ និងសេវាសុខាភិបាលឯកជនខុសច្បាប់ ដើម្បីសុខភាព និងសុវត្ថិភាពសង្គម

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ៣៣ សសរ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ
- បានឃើញសេចក្តីសម្រេចលេខ ១៥០ សសរ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

- បានឃើញប្រកាសរួមក្រសួងសុខាភិបាល និងក្រសួងព័ត៌មានលេខ ០០៧ អបស/មព និងលេខ ៧៥/០៦ ពមប្រក ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីលក្ខខណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបុរាណ គ្រឿងសំអាង ផលិតផលសម្រាប់ចញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- តាមសំណូមពរការងារចាំបាច់

# ស ម្រេ ច

**ប្រការ ១.~**

ប្រកាសរួមនេះមានគោលដៅ ដើម្បីការពារ និងលើកកម្ពស់សុខភាពសាធារណៈ សុវត្ថិភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ស្តីអំពី "ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ" ។

**ប្រការ ២.~**

គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវដាក់វិធានការរដ្ឋបាល និងផែនការសកម្មភាពជាបន្ទាន់ ក្នុងការគ្រប់គ្រងស្ថិតិ ឱសថស្ថាន ឱសថស្ថានរង អគារលក់ឱសថបុរាណ និងមជ្ឈមណ្ឌលថែរក្សាសម្ផស្សដែលមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល និងកន្លែងដែលគ្មានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាលដូចជា ផ្ទះលក់ឱសថ កន្លែងពិនិត្យព្យាបាលជំងឺមានលក់ឱសថ និងកន្លែងលក់ផលិតផលបំប៉នសុខភាព ឬអាហារបំប៉នសុខភាព ដោយប្រគល់ភារកិច្ច ទៅមន្ទីរសុខាភិបាល កំលាំងនគរបាល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលជាសេនាធិការ ចូលរួមធ្វើយុទ្ធនាការស្រង់ស្ថិតិទីកន្លែងមានច្បាប់-ឥតច្បាប់ឲ្យបានច្បាស់លាស់ ។ ក្នុងករណីមានកន្លែងលក់ឱសថគ្មានការអនុញ្ញាត ពីក្រសួងសុខាភិបាល និងសេវាសុខាភិបាលគ្រប់ប្រភេទមានលក់ឱសថ ត្រូវរៀបចំនីតិវិធី និងអនុវត្តតាមបទប្បញ្ញត្តិ ដើម្បីលុបបំបាត់ឲ្យបានជាស្ថាពរ ។

**ប្រការ ៣.~**

គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត ត្រូវដាក់វិធានការរដ្ឋបាល និងផែនការសកម្មភាពជាបន្ទាន់ក្នុងការគ្រប់គ្រងស្ថិតិទីតាំងប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ដូចជា បន្ទប់ថែទាំជំងឺ បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ព្យាបាលដោយចលនា បន្ទប់ពិគ្រោះព្យាបាលជំងឺ បន្ទប់ព្យាបាលជំងឺមាត់ធ្មេញ មន្ទីរព្យាបាលជំងឺមាត់ធ្មេញ មជ្ឈមណ្ឌលកែសម្ផស្ស មន្ទីរពិសោធន៍វេជ្ជសាស្ត្រ មន្ទីរសម្ភព មន្ទីរសម្រាកព្យាបាលជំងឺ មន្ទីរពហុព្យាបាលជំងឺ មន្ទីរពេទ្យឯកជន និងជាងធ្មេញ ដោយប្រគល់ភារកិច្ចទៅមន្ទីរសុខាភិបាល កំលាំងនគរបាល និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលជាសេនាធិការចូលរួមធ្វើយុទ្ធនាការស្រង់ស្ថិតិទីកន្លែង មានច្បាប់-ឥតច្បាប់ ឲ្យបានច្បាស់លាស់ ។ ក្នុងករណីចាំបាច់ ត្រូវចាត់វិធានការចំពោះសេវាសុខាភិបាលខុសច្បាប់ទាំងនោះ ត្រូវចងក្រងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី ។

**ប្រការ ៤.~**

ធ្វើការគ្រប់គ្រង និងចាត់វិធានការឲ្យបានតឹងរ៉ឹងបំផុត ចំពោះបុគ្គលដែលតាំងខ្លួនជាគ្រូពេទ្យព្យាបាលប្រជាពលរដ្ឋ បុគ្គលដើរលក់ឱសថជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលគ្មានការទទួលស្គាល់ពីក្រសួងសុខាភិបាល ។ ករណីរកឃើញបទល្មើសត្រូវចាត់វិធានការ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ ។

**ប្រការ ៥.~**

កងកំលាំងនគរបាលគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលប្រចាំការត្រួតពិនិត្យតាមច្រកទ្វារអន្តរជាតិ ច្រករបៀង តាមបន្ទាត់ព្រំដែនគោក ទឹក និងអាកាស ត្រូវសហការជាមួយស្ថាប័ន-អង្គភាពពាក់ព័ន្ធ និងភ្នាក់ងារត្រួតពិនិត្យសុខាភិបាល ដើម្បីធ្វើការតាមដានត្រួតពិនិត្យ និងបង្ក្រាបការនាំចូល ផលិតផលឱសថ អាហារបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព ឧបករណ៍បរិក្ខារពេទ្យ និងគ្រឿងសំអាង ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ៦.~**

អាជ្ញាធរមានសមត្ថកិច្ចនានាត្រូវសហការជាមួយ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល មន្ទីរពិសោធន៍ជាតិសុខភាពសាធារណៈ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា គ្រប់មន្ទីរសុខាភិបាល រាជធានី-ខេត្ត ក្នុងការស្រាវជ្រាវស៊ើបអង្កេត និងបង្ក្រាប ការផលិត ការនាំចូល ស្តុកទុក ចែកចាយផលិតផលឱសថ អាហារបំប៉នសុខភាព ឬផលិតផលបំប៉នសុខភាព ឧបករណ៍បរិក្ខារពេទ្យ គ្រឿងសំអាង និងប្រតិករគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ៧.~**

ត្រូវធានាឲ្យបាននូវភស្តុតាង និងជៀសវាងដាច់ខាតលើការសម្របសម្រួលក្រៅប្រព័ន្ធណាមួយ ដែលធ្វើអោយជនល្មើសរួចផុតពីសំណាញ់ច្បាប់ ។ អាជ្ញាធរមានសមត្ថកិច្ចទាំងឡាយណាដែលចូលរួមផ្សំគំនិត ឬផ្តល់លទ្ធភាពឲ្យប្រព្រឹត្តបទល្មើស ឬបំណងបន្ធូរបន្ថយទោស ឬភស្តុតាងដាក់បន្ទុកលើជនល្មើស ត្រូវទទួលពិន័យរដ្ឋបាល និងទោសដាក់ពន្ធនាគារ ។

**ប្រការ ៨.~**

ចូលរួមសហការជាមួយស្ថាប័នពាក់ព័ន្ធនានា គ្រប់ប្រព័ន្ធផ្សព្វផ្សាយ ជួយអប់រំដល់ប្រជាពលរដ្ឋឲ្យបានយល់ជ្រួតជ្រាបអំពីផលប៉ះពាល់ និងភាពងាយរងគ្រោះ ដល់សុខភាពសាធារណៈ ដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលសុខាភិបាល និងសេវាសុខាភិបាលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ៩.~**

ធ្វើការគ្រប់គ្រង និងចាត់វិធានការយ៉ាងតឹងរ៉ឹងទៅតាមបទប្បញ្ញត្តិ ចំពោះការផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់រូបភាពទាក់ទងនឹងវិស័យសុខាភិបាល ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ១០.~**

អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវរៀបចំធ្វើរបាយការណ៍អំពីលទ្ធផល និងសកម្មភាពការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មកគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដែលមានលេខាធិការដ្ឋាន នៅក្រសួងមហាផ្ទៃ និងគណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ ដែលមានលេខាធិការដ្ឋាន នៅនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល ដើម្បីពិនិត្យ តាមដានការអនុវត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងស្នើដាក់ចេញវិធានការបន្ត។

**ប្រការ ១១.-**

អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាននគរបាលអន្តោប្រវេសន៍ គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម គណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ គណៈអភិបាលរាជធានី-ខេត្ត អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល មន្ទីរពិសោធន៍ជាតិសុខភាពសាធារណៈ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ស្ថាប័ន-អង្គភាពពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តតាមប្រកាសរួមនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៧ ឆ្នាំ ២០១៥

លេខៈ ១៤៦ ប្រ.ក លេខៈ ០០៤ អ.ហ.ត/ស្ស មហាផ្ទៃ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ស ខេង** **ម៉ម ប៊ុនហេង**

**ចម្លងជូនៈ**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា-រដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងការពារជាតិ
- -ក្រសួងយុត្តិធម៌
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងព័ត៌មាន
- -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- -ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- -ដូចប្រការ ១១

"ដើម្បីអនុវត្ត"

- -ឯកសារ កាលប្បវត្តិ